# គំរូរបស់ព្រះយេស៊ូវសម្រាប់ការរីកចម្រើនឡើង និងការបម្រើ
# Jesus' Model for Growth and Service

## សេចក្តីសង្ខេប:

លោកលូកាបង្រៀនយើងថា ព្រះយេស៊ូវបានចម្រើនវ័យឡើងខាងសាច់ឈាម ខាងវិញ្ញាណ ខាងសង្គម និងមានប្រាជ្ញា។ ព្រះអង្គបានត្រលប់ជាសព្វគ្រប់ទាំងអស់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ព្រះអង្គជាអ្នកដែលបម្រើស្តាប់បង្គាប់ និងពិតប្រាកដ។ ព្រះអង្គគឺជាគំរូរបស់យើងសម្រាប់ការរីកចម្រើនឡើងនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង និងសម្រាប់បម្រើអ្នកដទៃទៀត ដើម្បីជួយពួកគេឱ្យរីកចម្រើនឡើងទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ។

## គំនិតចម្បង:

១. ព្រះយេស៊ូវបានរីកចម្រើនឡើងនៅក្នុងបួនផ្នែក: ប្រាជ្ញា សាច់ឈាម វិញ្ញាណ និងសង្គម។ នេះក៏ជាគំរូដ៏ល្អផងដែរសម្រាប់ការរីកចម្រើនឡើងគ្រប់ជ្រុងជ្រោយនៅក្នុងជីវិតរបស់យើង។

២. ព្រះអង្គបានវិវឌ្ឍឡើងយ៉ាងគ្រប់លក្ខណ៍ ទោះបីជាលក្ខខណ្ឌមិនគ្រប់លក្ខណ៍ក៏ដោយ។

៣. គោលបំណងរបស់ព្រះយេស៊ូវនៅក្នុងការវិឌ្ឍន៍ឡើងគឺដើម្បីក្លាយទៅជាអ្នកបម្រើដែលស្តាប់បង្គាប់ គឺបម្រើឱ្យរបៀបវារៈរបស់ព្រះជាម្ចាស់ និងធ្វើដំណើរឆ្ពោះទៅរកគោលបំណងពេញលេញរបស់ព្រះជាម្ចាស់។

៤. ការវិឌ្ឍន៍របស់មនុស្សដែលល្អបំផុតគឺជាការធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់នៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។

៥. គោលបំណងរបស់យើងគឺបម្រើឱ្យរបៀបវារៈរបស់ព្រះជាម្ចាស់ ដែលរួមមានការជួយមនុស្សដទៃទៀតឱ្យរីកចម្រើនឡើងឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។

## លទ្ធផល:

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តជំហានថ្មីមួយជាការឆ្លើយតបទៅនឹងគំនិតចម្បងនៅក្នុងមេរៀននេះ ដើម្បីរីកចម្រើនឡើងនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត និងវិវឌ្ឍទៅជាអ្នកបម្រើ។

២. ទៅមុខទៀត

ក. ដឹងថា ព្រះយេស៊ូវបានរីកចម្រើនឡើងគ្រប់ជ្រុងជ្រោយ ដើម្បីក្លាយទៅជាអ្នកបម្រើឱ្យគោលបំណងរបស់ព្រះជាម្ចាស់ និងប្ដេជ្ញាចិត្តរីកចម្រើនឡើងនៅក្នុងផ្នែកទាំងបួនក្នុងជីវិតរបស់ពួកគេ។

ខ. ប្ដេជ្ញាចិត្តបម្រើមនុស្សដទៃទៀត ដោយជួយពួកគេឱ្យរីកចម្រើនឡើង ដូចជាព្រះយេស៊ូវបានរីកចម្រើនឡើងនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត ហើយរស់នៅជាអ្នកបម្រើ។

# គំរូរបស់ព្រះយេស៊ូវសម្រាប់ការរីកចម្រើនឡើង និងការបម្រើ

## គ្រោងមេរៀន

## ១. រំឭកមេរៀនឡើងវិញ

## ២. សេចក្តីផ្តើម

## ៣. ខគម្ពីរគន្លឹះ: លូកា ២:៥២

ក. តើនរណាគឺជាអ្នកដែលវិវឌ្ឍន៍ខ្លាំងជាងគេបំផុត?

ខ. តើពាក្យសាមញ្ញដែលត្រូវបានប្រើសម្រាប់ការរីកចម្រើនឡើងរបស់ព្រះយេស៊ូវមានពាក្យអ្វីខ្លះ?

គ. តើព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់អំពីផ្នែកទាំងនេះនៅក្នុងការរីកចម្រើនឡើងរបស់យើងដែរឬទេ?

ឃ. តើការវិវឌ្ឍន៍របស់ព្រះយេស៊ូវកើតឡើងភ្លាម ឬជាដំណើរការ?

ង. តើមានការប្រាប់ដោយប្រយោលអ្វីខ្លះសម្រាប់ក្រុមជំនុំ?

## ៤. លក្ខខណ្ឌនៃការវិឌ្ឍន៍របស់ព្រះយេស៊ូវ

ក. នយោបាយ

ខ. សេដ្ឋកិច្ច

គ. ការងារ

ឃ. ការអប់រំ

ង. ឋានៈក្នុងសង្គម

ច. គ្រួសារ

ឆ. វិញ្ញាណ

## ៥. លក្ខខណ្ឌជាមូលដ្ឋានគ្រឹះសម្រាប់ការរីកចម្រើនឡើង

## ៦. និយមន័យអំពីការវិវឌ្ឍន៍របស់មនុស្ស

## ៧. គោលបំណងសម្រាប់ការវិវឌ្ឍន៍ឡើងរបស់ព្រះយេស៊ូវ

*យ៉ូហាន ១២:៤៩-៥០, ១៤:៣១, លូកា ៤:១៨-១៩, ម៉ាថាយ ៤:២៣-២៤, ៩:៣៥-៣៦, ម៉ាថាយ ២០:២៥-២៨។*

- តើគោលបំណង ឬគោលដៅរបស់ព្រះយេស៊ូវនៅក្នុងជីវិត និងព័ន្ធកិច្ចរបស់ព្រះអង្គគឺជាអ្វី? តើនរណាបានកំណត់គោលបំណងនោះ?

- តើការរីកចម្រើនឡើងរបស់ព្រះយេស៊ូវ ( លូកា ២:៥២) បានរៀបចំព្រះអង្គសម្រាប់ព័ន្ធកិច្ចរបស់ព្រះអង្គយ៉ាងដូចម្ដេច?

- តើព្រះយេស៊ូវធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ព្រះអង្គយ៉ាងដូចម្ដេច?

- ហេតុអ្វីបានជាការធ្វើជាអ្នកបម្រើមានសារៈសំខាន់ខ្លាំងម្ល៉េះសម្រាប់គោលបំណងនៅក្នុងជីវិតរបស់ព្រះយេស៊ូវ និងនៅក្នុងជីវិតរបស់យើង?

## ៨. គោលបំណងសម្រាប់ការរីកចម្រើននៃសិស្សរបស់ព្រះយេស៊ូវ

*ម៉ាថាយ ១០:៥-៨, ម៉ាកុស ៩:៣៥, យ៉ូហាន ១៤:១៥, ២១, ២៣, ២៤ យ៉ូហាន ១៣:៣៤-៣៥*

- តើព្រះយេស៊ូវបានចាត់សិស្សរបស់ព្រះអង្គឱ្យចេញទៅធ្វើអ្វី?

- តើព្រះយេស៊ូវពណ៌នាអំពីរបៀបដែលសិស្សរបស់ព្រះអង្គក្លាយទៅជាអ្នកធំយ៉ាងដូចម្ដេច?

- យោងទៅតាមយ៉ូហាន ១៤ យើងកាន់តែចម្រើនឡើង យើងក៏កាន់តែត្រូវ____________________

- តើបញ្ញត្តិមួយចំនួនដែលយើងត្រូវស្ដាប់បង្គាប់តាមមានអ្វីខ្លះ?

## ៩. ការរីកចម្រើនចាប់ផ្ដើមជាមួយខ្ញុំ

## ១០. ការពង្រឹងគំនិតគន្លឹះឡើងវិញ

## ១១. ផែនការអនុវត្ត

ក. ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

- ចូរគិតរកគំនិតមួយចំនួនអំពីរបៀបដែលលោកអ្នកត្រូវធ្វើនៅក្នុងផ្នែកនិមួយៗដែលមាននៅក្នុងលូកា ២:៥២ ដែលជាគំរូរបស់ព្រះយេស៊ូវ ។

ខ. ផែនការអនុវត្តក្នុងម៉ោង

| **គំនិតរបស់ខ្ញុំសម្រាប់ការវិវឌ្ឍន៍ផ្ទាល់ខ្លួន** | |
|---|---|
| សម្រាប់ផ្នែកនិមួយៗខាងក្រោម ចូរសរសេរកិច្ចការមួយដែលលោកអ្នកអាចធ្វើបានដើម្បីរីកចម្រើនឡើងនៅក្នុងផ្នែកនោះ ។ | |
| **ខាងប្រាជ្ញា** | |
| **ខាងសាច់ឈាម** | |
| **ខាងវិញ្ញាណ** | |
| **ខាងសង្គម** | |

| **ផែនការអនុវត្តផ្ទាល់ខ្លួនរបស់ខ្ញុំ និងការប្តេជ្ញាចិត្ត** | |
|---|---|
| ជ្រើសរើសយកផ្នែកមួយ គួររង្វង់ជុំវិញផ្នែកនោះ និងរៀបចំផែនការជាក់លាក់សម្រាប់កិច្ចការមួយដែលលោកអ្នកនឹងធ្វើនៅសប្តាហ៍នេះ ដើម្បីរីកចម្រើនឡើងនៅក្នុងផ្នែកមួយនៃផ្នែកទាំងបួន ។ | |
| **ខាងប្រាជ្ញា** | **អ្វី?** |
| **ខាងសាច់ឈាម** | **នរណា?** |
| **ខាងវិញ្ញាណ** | **នៅពេលណា?** |
| **ខាងសង្គម** | **នៅកន្លែងណា?** |

| តម្រូវការឱ្យមានការវិវឌ្ឍន៍នៅក្នុងគ្រួសាររបស់ខ្ញុំ | | | | |
|---|---|---|---|---|
| សម្រាប់ផ្នែកនិមួយៗខាងក្រោម សូមបញ្ជាក់ប្រាប់ឧទាហរណ៍មួយអំពីតម្រូវការឱ្យមានការវិវឌ្ឍន៍នៅក្នុងគ្រួសាររបស់ខ្ញុំ។ | | | | |
| **ផ្នែកទាំងបួននៃការវិវឌ្ឍន៍** | **ប្រាជ្ញា** | **សាច់ឈាម** | **វិញ្ញាណ** | **សង្គម** |
| **គ្រួសារ** | | | | |

| ផែនការបម្រើសម្រាប់ការវិវឌ្ឍន៍ឡើងរបស់អ្នកជទៃ និងការប្ដេជ្ញាចិត្ត | |
|---|---|
| ជ្រើសរើសផ្នែកមួយ គួររង្វង់ជុំវិញផ្នែកនោះ និងរៀបចំផែនការជាក់លាក់សម្រាប់កិច្ចការមួយដែលលោកអ្នកនឹងធ្វើនៅពេលឆាប់ៗនេះដើម្បីជួយពួកគេឱ្យរីកចម្រើនឡើង (ធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ) នៅក្នុងផ្នែកមួយនៃផ្នែកទាំងបួន។ | |
| **ប្រាជ្ញា** | **អ្វី?** |
| **សាច់ឈាម** | **នរណា?** |
| **វិញ្ញាណ** | **នៅពេលណា?** |
| **សង្គម** | **នៅកន្លែងណា?** |

# គំរូរបស់ព្រះយេស៊ូវសម្រាប់ការរីកចម្រើនឡើង និងការបម្រើ
## មេរៀន

ជីវិតរបស់ព្រះយេស៊ូវនៅលើផែនដីផ្តល់ឱ្យយើងនូវគំរូមួយអំពីការរីកចម្រើនឡើងដែលខុសប្លែកយ៉ាងខ្លាំងពីទស្សនៈរបស់លោកិយអំពីការវិវឌ្ឍន៍របស់មនុស្ស ហើយគំរូនោះអាចធ្វើជាបទដ្ឋាននៅក្នុងព្រះគម្ពីរសម្រាប់ជីវិតរស់នៅរបស់យើង។ តើលោកិយមានទស្សនៈយ៉ាងដូចម្តេចអំពីការវិវឌ្ឍន៍? សង្គមលោកិយឱ្យនិយមន័យការវិវឌ្ឍន៍ផ្អែកលើការអប់រំ និងសម្ភារៈ។ ការអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ត្រូវបានចាត់ទុកជាយន្តការីចម្បង ដើម្បីនឹងលប់បំបាត់ចោលភាពក្រីក្រ បំពេញសេចក្តីត្រូវការខាងសាច់ឈាម និងស្វែងរកសន្តិភាព និងសុភមង្គល។

ការអប់រំខ្ពង់ខ្ពស់ បច្ចេកវិទ្យាទំនើប ផលិតកម្មឧស្សាហកម្ម សេដ្ឋកិច្ចជាតិរីកចម្រើនឡើង និង ទិន្នផលសរុបប្រចាំឆ្នាំខ្ពស់ បានទទួលការឱ្យតម្លៃទៅតាមគំនិតរបស់លោកិយអំពីការវិវឌ្ឍន៍។ ខណៈពេលដែលការអប់រំ បច្ចេកវិទ្យា និងផលប្រយោជន៍ដទៃទៀតរបស់វប្បធម៌លោកខាងលិចមានប្រយោជន៍នៅក្នុងការលើកស្ទួយជីវិតដែលមានការអប់រំ និងទ្រព្យសម្បត្តិ ទាំងអស់នោះមិនមែនជាលក្ខខណ្ឌគ្រឹះសម្រាប់ការរីកចម្រើនឡើងឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់ទេ។

គួរឱ្យសោកស្តាយ គ្រីស្ទបរិស័ទជាច្រើនដែលមកពីប្រទេសតតិយលោកបានទទួលយកគំរូរបស់លោកិយដោយមិនដឹងខ្លួនតាមរយៈការអូសទាញរបស់សម្ភារៈនិយម។ ពួកគេបានជឿការកុហកដែលប្រាប់ថា ការអប់រំ និងបច្ចេកវិទ្យារបស់លោកខាងលិចគឺជានាវាដែលនាំពួកគេ និងប្រជាជនរបស់ពួកគេទៅដល់ត្រើយនៃសុភមង្គល។ អ្នកទាំងនោះមិនមានកំហុសទេ។ បងប្អូនប្រុសស្រីរបស់ពួកគេដែលនៅលោកខាងលិចត្រូវបានអូសទាញជាមុន បន្ទាប់មក បេសកជនដែលមកពីប្រទេសខាងលិចបាននាំយកសារមក ដែលជាញើកញាប់វេចខ្ចប់នៅក្នុងគំនិតសម្ភារៈនិយម។ ជាញើកញាប់ ពួកអ្នកជឿនៅប្រទេសតតិយលោក"បាបចាប់យក"ទស្សនៈនៃការវិវឌ្ឍន៍បែបសម្ភារៈនិយមនោះ។

បេសកជន និងបុគ្គលិកអភិវឌ្ឍ និងជួយសង្គ្រោះដែលជាគ្រីស្ទបរិស័ទក៏បានលើកស្ទួយទស្សនៈនៃការវិវឌ្ឍន៍បែបសម្ភារៈនិយមនេះផងដែរ តាមរយៈរបៀបដែលពួកគេរស់នៅ ទោះបីជាដោយអចេតនាក៏ដោយ។ ប្រសិនបើអ្នកក្រជឿព្រះគ្រីស្ទតាមរយៈការធ្វើទីបន្ទាល់របស់អ្នក"មាន" (អ្នកដែលមាននាឡិកាដៃ កាំមេរ៉ា កុំព្យូទ័រ ឡាន ឬសម្លៀកបំពាក់ល្អៗ) តើអ្នកក្រនោះអាចមានគំនិតយល់យ៉ាងដូចម្តេចអំពីការក្លាយខ្លួនជាគ្រីស្ទបរិស័ទ និងការមានទ្រព្យសម្បត្តិ? ប្រសិនបើទីភ្នាក់ងារអភិវឌ្ឍរបស់គ្រីស្ទបរិស័ទប្រើបច្ចេកវិទ្យានៅក្នុងសហគមន៍មួយដែលថ្លៃលើសជាងប្រាក់

ចំណូលប្រចាំឆ្នាំរបស់ប្រជាជនមូលដ្ឋានបូកសរុបចូលគ្នាទៅទៀតនោះ តើសហគមន៍នោះនឹងយល់យ៉ាងដូចម្ដេចអំពីទំនាក់ទំនងរវាងជំនឿគ្រីស្ទបរិស័ទ បច្ចេកវិទ្យាទំនើប និងការអភិវឌ្ឍន៍?

## លូកា ២:៥២

គ្រីស្ទបរិស័ទត្រូវប្រៀបធៀបជំនឿរបស់ខ្លួនអំពីការអភិវឌ្ឍន៍ជាមួយបទគម្ពីរ។ នៅក្នុងលូកា ២:៥២ យើងសង្កេតឃើញការបង្ហាញដ៏ច្បាស់លាស់ជាងគេបំផុតមួយអំពីទស្សនៈនៅក្នុងព្រះគម្ពីរអំពីការអភិវឌ្ឍន៍របស់មនុស្ស។ "ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង"។ ព្រះយេស៊ូវគឺជាឧទាហរណ៍យ៉ាងគ្រប់លក្ខណ៍មុនគេបង្អស់អំពីអ្វីដែលព្រះជាម្ចាស់ចង់បាន នៅពេលដែលព្រះអង្គបានបង្កើតមនុស្សឱ្យមានរូបអង្គដូចជាទ្រង់។ នៅពេលដែលលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាប ពួកគេបានបាត់បង់ភាពគ្រប់លក្ខណ៍ដែលពួកគេត្រូវបានបង្កើតមកនោះ។ ឥឡូវនេះ នៅក្នុងព្រះយេស៊ូវ យើងអាចមើលឃើញគំរូដ៏គ្រប់លក្ខណ៍អំពីរូបអង្គរបស់ព្រះជាម្ចាស់បាន។ ជាលើកដំបូងហើយចាប់តាំងពីការបង្កើតលោកមក ដែលយើងអាចមើលឃើញអ្វីដែលយើងត្រូវក្លាយទៅជា។ ដោយព្រោះព្រះយេស៊ូវគ្រប់លក្ខណ៍ ព្រះអង្គគឺជាគំរូរបស់យើង ហើយការអភិវឌ្ឍន៍របស់ព្រះអង្គអាចធ្វើជាគំរូសម្រាប់ការរីកចម្រើនឡើងរបស់យើងបាន។

សូមពិចារណាការពាក់ព័ន្ធមួយចំនួននៅក្នុងលូកា ២:៥២។ ទីមួយ បទគម្ពីរនេះចង្អុលប្រាប់ពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងមូល។ លោកគ្រូពេទ្យលូកាបានពណ៌នាបួនផ្នែកដែលព្រះយេស៊ូវបានរីកចម្រើនឡើង។ ព្រះអង្គបានរីកចម្រើនឡើងខាងប្រាជ្ញា ហើយព្រះអង្គក៏បានរីកចម្រើនឡើងខាងសាច់ឈាម ខាងសង្គម និងខាងវិញ្ញាណផងដែរ។ គ្រីស្ទបរិស័ទភាគច្រើនបានយល់ព្រមថា ព្រះយេស៊ូវគឺជាអ្នកដែលបានវិវឌ្ឍខ្លាំងជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រទាំងមូល។ ព្រះគម្ពីរកត់ត្រាការវិវឌ្ឍន៍ខាងសាច់ឈាម និងខាងសង្គមរបស់ព្រះយេស៊ូវ ព្រមទាំងការវិវឌ្ឍន៍ខាងវិញ្ញាណរបស់ព្រះអង្គផងដែរ។ ច្បាស់ណាស់ ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ចង់ឱ្យព្រះយេស៊ូវបានរីកចម្រើនឡើងនៅក្នុងផ្នែកនិមួយៗទាំងនេះ ដើម្បីសម្រេចគោលបំណងដែលព្រះអង្គបានយាងចូលមកក្នុងពិភពលោកនេះ។ ប្រសិនបើការរីកចម្រើនឡើងរបស់ព្រះយេស៊ូវគឺជាគំរូសម្រាប់ការរីកចម្រើនឡើងរបស់យើង យើងអាចដឹងបានថា ព្រះជាម្ចាស់ក៏យកព្រះហឫទ័យទុកដាក់អំពីការវិវឌ្ឍន៍ឡើងរបស់យើងនៅក្នុងផ្នែកនិមួយៗនេះផងដែរ។

ដោយព្រោះព្រះយេស៊ូវគឺជាគំរូរបស់យើងសម្រាប់ការវិវឌ្ឍន៍ឡើង មានសេចក្ដីផ្សេងទៀតដែលយើងត្រូវតែទទួលស្គាល់ផងដែរ។ ពាក្យ "កាន់តែធំ" ប្រាប់ថា ការរីកចម្រើនឡើងរបស់ព្រះយេស៊ូវគឺជាដំណើរការផងដែរ។ ព្រះអង្គ *បានចម្រើនឡើង* នៅក្នុងផ្នែកនិមួយៗនេះ។ ចូរស្រមៃមើលពីទិដ្ឋភាពនេះ: ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះជា

ម្ចាស់បានឆ្លងកាត់ដំណើរការនៃការរីកចម្រើនឡើង។ ផែនការរបស់ព្រះជាម្ចាស់សម្រាប់យើងគឺឱ្យយើងរីកចម្រើនឡើងផងដែរ។ នៅសព្វថ្ងៃនេះ យើងទាំងអស់គ្នាកំពុងតែនៅក្នុងដំណើរការនៃការរីកចម្រើនឡើង និងការវិវឌ្ឍន៍ឡើង។ ដោយពិចារណាគំនិតទាំងនេះ តើមានការប្រាប់ដោយប្រយោលអ្វីខ្លះនៅក្នុងលូកា ២:៥២ សម្រាប់ការវិឌ្ឍន៍ឡើងផ្ទាល់ខ្លួនរបស់លោកអ្នក និងសម្រាប់ពួកជំនុំ?

យើងអាចចែកចំណាត់ថ្នាក់ផ្នែកភាគច្រើន ឬទាំងអស់នៃការវិវឌ្ឍន៍របស់មនុស្សនៅក្រោមប្រភេទមួយ ឬច្រើននៅក្នុងប្រភេទទាំងបួនដែលមាននៅក្នុងកណ្ឌគម្ពីរលូកា។ មិនត្រឹមតែមានប្រាជ្ញានៅក្នុងលក្ខណៈដ៏ទូលំទូលាយរបស់ប្រភេទទាំងនេះទេ ថែមទាំងជារបៀបសាមញ្ញដែលប្រភេទទាំងនោះអនុញ្ញាតឱ្យយើងមើលឃើញមនុស្សទាំងមូល និងសារៈប្រយោជន៍របស់ប្រភេទទាំងនោះជាវិធីដើម្បីពិចារណាការបម្រើដល់មនុស្សដទៃទៀត។ ប្រភេទទាំងនេះបានត្រលប់ជាគ្រឹះសម្រាប់ឧបករណ៍ព័ន្ធកិច្ចរបស់ Harvest និងជាគំរូថ្មីសម្រាប់ការរីកចម្រើនឡើងរបស់សហគមន៍នៅជុំវិញពិភពលោក។ នៅដើមឆ្នាំ ១៩៨០ ខណៈពេលដែលកំពុងធ្វើដំណើរនៅក្នុងប្រទេសហុងឌូរ៉ាស លោក បប់កំពុងធ្វើដំណើរកាត់តាមសហគមន៍អនាធិបតេយ្យមួយ នោះមានបុរសម្នាក់បានដើរមកជួបគាត់ ហើយនិយាយថា "ព្រះយេស៊ូវបានចម្រើនឡើងខាងប្រាជ្ញា ខាងសាច់ឈាម ខាងវិញ្ញាណ និងខាងសង្គម ហើយយើងគួរតែរីកចម្រើនឡើងតាមរបៀបដូចគ្នានោះដែរ"។ គាត់បានប្រាប់ថា គាត់បានចូលរួមរៀនកាលពីពីរឆ្នាំមុន និងបានរៀនសេចក្តីពិតនេះ។ នោះគឺជារឿងមួយក្នុងចំណោមរឿងជាច្រើនដែលបានបញ្ជាក់ប្រាប់យើងថា គំរូរបស់លោកលូកាសម្រាប់ការរីកចម្រើនឡើងគឺជាឧបករណ៍ដែលមានសារៈប្រយោជន៍។

## លក្ខខណ្ឌសម្រាប់ការវិវឌ្ឍន៍ឡើងរបស់ព្រះយេស៊ូវ

ព្រះយេស៊ូវសម្រេចបានសក្តានុពលពេញលេញជាមនុស្សរបស់ព្រះអង្គនៅក្នុងផ្នែកទាំងបួននេះនៅក្នុងបរិបទមួយដែលមិនសូវមានទ្រព្យសម្បត្តិ។ ព្រះអង្គបានប្រសូតមកនៅក្នុងក្រោលសត្វ។ ព្រះអង្គគឺជាជនភៀសខ្លួនខាងនយោបាយនៅក្នុងស្រុកអេស៊ីព្ទ។ ព្រះអង្គបានធំឡើងនៅក្នុងផ្ទះពលករជំនាញមួយរូបនៅណាសារ៉ែត ជាទីក្រុងតូចមួយដែលត្រូវរ៉ូមគាបសង្កត់។ គ្រួសាររបស់ព្រះអង្គមានសីលធម៌ ប៉ុន្តែដោយព្រោះការមកចាប់ទំផ្ទៃបែបចម្លែករបស់ព្រះអង្គ មនុស្សបានមើលមកគ្រួសាររបស់ព្រះអង្គដោយមានការសង្ស័យ និងការវិនិច្ឆ័យខ្លះ។ ដោយព្រោះតែយើងមិនបានឮអំពីលោកយ៉ូសែប ក្រោយពីពួកគេទៅក្រុងយេរូសាឡិមនោះ លោកប្រហែលជាស្លាប់នៅវ័យក្មេងនៅឡើយ ហើយព្រះយេស៊ូវទំនងជាក្លាយទៅជាអ្នកផ្គត់ផ្គង់ចម្បងសម្រាប់គ្រួសារ ដោយធ្វើជាជាងឈើ។ ព្រះយេស៊ូវមិនមានការអប់រំក្នុងប្រព័ន្ធខ្ពង់ខ្ពស់ទេ ប៉ុន្តែការអប់រំរបស់ព្រះអង្គគ្រប់គ្រាន់ល្មមទៅតាមខ្នាតនៅក្នុងមូលដ្ឋាន គឺព្រះអង្គអាចអានបាន

សរសេរបាន ព្រមទាំងចេះបទគម្ពីរយ៉ាងច្បាស់ ។ នៅក្នុងផ្ទះរបស់ព្រះយេស៊ូវ មិនមានទឹកស្អាត បង្គន់សម័យទំនើប ចរន្ត អគ្គិសនី ឬទូរទស្សន៍ទេ ។ ព្រះអង្គមិនមាននាឡិកាដៃ ឡាន ឬកុំព្យូទ័រទេ ។

ព្រះយេស៊ូវសម្រេចបានសក្ដានុពលពេញលេញរបស់ព្រះអង្គដោយមិនមានទ្រព្យសម្បត្តិហូរហៀរ ការអប់រំខ្ពង់ខ្ពស់ ឬបច្ចេកវិទ្យាទំនើបទេ។ ព្រះអង្គបានប្រាប់សិស្សរបស់ព្រះអង្គថា "ជីវិតនៃមនុស្សមិនស្រេចនឹងបានទ្រព្យសម្បត្តិជាបរិបូរទេ" (លូកា ១២:១៥) ។ តាមខ្នាតរបស់យើង ព្រះយេស៊ូវប្រហែលជាក្រ ប៉ុន្តែព្រះអង្គមិនមែនទ័លក្រទេ។ ភាពទ័លក្រមិនមែនជាគោលបំណងរបស់ព្រះជាម្ចាស់ទេ។ ព្រះយេស៊ូវមានសេចក្ដីស្រលាញ់ ការឧបត្ថម្ភ និងឱកាសរៀនសូត្រគ្រប់គ្រាន់ ព្រមទាំងមានទ្រព្យសម្បត្តិដែលចាំបាច់សម្រាប់សម្រេចគោលបំណងរបស់ព្រះជាម្ចាស់ ។ ទ្រព្យសម្បត្តិដែលព្រះជាម្ចាស់បានផ្គត់ផ្គង់សម្រាប់ការរីកចម្រើនរបស់ព្រះយេស៊ូវមិនមែនបរិបូរទេ ក៏មិនមែនទ័លក្រដែរ គឺគ្រប់គ្រាន់។ គ្រប់គ្រាន់មានន័យថា មានធនធានគ្រប់គ្រាន់ដើម្បីបំពេញសេចក្ដីត្រូវការជាមូលដ្ឋានគ្រឹះ។ ភាពគ្រប់គ្រាន់ត្រូវបានពណ៌នាយ៉ាងប៉ិនប្រសប់នៅក្នុងសុភាសិត ៣០:៨-៩ ដែលចែងថា "សូមកុំឱ្យទូលបង្គំមានសេចក្ដីទ័លក្រ ឬជាអ្នកមានដែរ សូមគ្រាន់តែចិញ្ចឹមទូលបង្គំដោយអាហារដែលត្រូវការប៉ុណ្ណោះ ក្រែងទូលបង្គំបានឆ្អែត ហើយបោះបង់ចោលទ្រង់ដោយពាក្យថា ព្រះយេហូវ៉ាជាអ្នកណាហ្ន៎ ឬក្រែងទូលបង្គំមានសេចក្ដីទ័លក្រ ហើយទៅជាលួចគេ ព្រមទាំងប្រើព្រះនាមនៃព្រះជាទីមើលងាយផង" ។

លក្ខខណ្ឌខាងសាច់ឈាមសម្រាប់ការរីកចម្រើនរបស់ព្រះយេស៊ូវផ្ដល់សេចក្ដីសង្ឃឹមយ៉ាងធំដល់មនុស្សជាច្រើននៅពាសពេញពិភពលោកដែលមិនមានព្រះពរជាភាពបរិបូរខាងសាច់ឈាម ។ នេះបង្ហាញឱ្យឃើញថា មនុស្សអាចសម្រេចគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេបាននៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត ដោយមិនចាំបាច់មានបរិបូរឡើយ ដូចជាទឹកស្អាត ចរន្តអគ្គិសនី ការងារប្រាក់ខែច្រើន បច្ចេកវិទ្យា ឬការអប់រំខ្ពង់ខ្ពស់ ។ ជំនឿដែលជឿថា ភាពបរិបូរគឺជាលក្ខខណ្ឌសម្រាប់ការរីកចម្រើន គឺជាជំនឿលើការថ្វាយបង្គំរូបព្រះ ដែលបានធ្វើឱ្យពិការដល់ភាពស្វាហាប់ខាងវិញ្ញាណរបស់គ្រីស្ទបរិស័ទជាច្រើននៅលោកខាងលិច ។ ជាញឹកញាប់ ទស្សនៈនេះផ្ដោតលើការពឹងផ្អែកលើ "ទ្រព្យសម្បត្តិ"សម្រាប់សុភមង្គល និងភាពជោគជ័យ ប៉ុន្តែទស្សនៈនៅក្នុងព្រះគម្ពីរបង្ហាញប្រាប់ការពឹងផ្អែកលើព្រះជាម្ចាស់។ "ទ្រព្យសម្បត្តិ"អាចជាជំនួយយ៉ាងធំដល់ការរីកចម្រើន ប៉ុន្តែប្រសិនបើគេចាត់ទុកថាទ្រព្យសម្បត្តិជាមាគ៌ាសម្រាប់ការរីកចម្រើន នោះយើងផ្ដោតអារម្មណ៍ខុស និងរំពឹងទុកខុសហើយ ។ ព្រះជាម្ចាស់គឺជាប្រភព និងជាអ្នកផ្គត់ផ្គង់សម្រាប់យើង ដូចដែលព្រះអង្គគឺជាប្រភព និងជាអ្នកផ្គត់ផ្គង់សម្រាប់ព្រះយេស៊ូវ ។ អ្នកដែលមានគ្រប់គ្រាន់ ប៉ុន្តែក្រ ដូចជាព្រះយេស៊ូវ សុទ្ធតែអាចរីកចម្រើនឡើង និងសម្រេចគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់ពួកគេ ដូចជាព្រះអង្គដែរ ។ ម្ដងទៀត ការអប់រំ ឬទ្រព្យសម្បត្តិអាចជារបស់ល្អ ប៉ុន្តែមិនមែន

ជាលក្ខខណ្ឌគ្រឹះសម្រាប់ការវិវឌ្ឍន៍ឡើងទេ។ ទស្សនៈនៅក្នុងព្រះគម្ពីរនេះរំដោះមនុស្សឱ្យមានសេរីភាព។ ប្រសិនបើមនុស្សមានគ្រប់គ្រាន់ ប៉ុន្តែខ្វះ"របស់"ដែលមាននៅក្នុងប្រទេសលោកខាងលិច ពួកគេមិនត្រូវបានរារាំងពីការប្រែក្លាយទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ពួកគេទេ។ ការវិវឌ្ឍន៍ឡើងនៅក្នុងព្រះគម្ពីរអាចជួយមនុស្សជាច្រើនឱ្យធ្វើដំណើរឆ្ពោះទៅរកការសម្រេចបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយកម្លាំងថាមពលរបស់មនុស្សអាចត្រូវបានតម្រង់ឆ្ពោះទៅរកការប្រែក្លាយទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ មិនមែនទៅលើការខិតខំប្រឹងប្រែងឱ្យមាន"ទ្រព្យសម្បត្តិ"កាន់តែច្រើនទេ។

## ការធ្លាប់ដោយប្រយោលសម្រាប់ពួកជំនុំ

គំរូអំពីការរីកចម្រើនឡើងរបស់ព្រះយេស៊ូវប្រាប់ដោយប្រយោលថា គ្រីស្ទបរិស័ទដែលយកចិត្តទុកដាក់អំពីការវិវឌ្ឍន៍ឡើងត្រូវធ្វើការឆ្ពោះទៅរកបរិបទគ្រប់គ្រាន់ដែលមនុស្សអាចរីកចម្រើនឡើងបាន។ គំរូនេះក៏ប្រាប់ដោយប្រយោលផងដែរថា ពួកជំនុំមានការទទួលខុសត្រូវសម្រាប់ភាពគ្រប់គ្រាន់។ យើងជឿថា ព្រះជាម្ចាស់ចង់ឱ្យមនុស្សទាំងអស់មានធនធានដែលចាំបាច់ដើម្បីរីកចម្រើនឡើងទៅរកភាពពេញវ័យ។ សេចក្តីនេះមិនអាចទៅរួចឡើយនៅក្នុងពិភពលោកដែលមានបាប ប៉ុន្តែបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺមិនឱ្យមនុស្សខ្វះអ្វីដែលពួកគេត្រូវការដើម្បីរីកចម្រើនឡើងឆ្ពោះទៅរកគោលបំណងដែលព្រះជាម្ចាស់បានបង្កើតពួកគេមកនោះឡើយ។ យើងកត់សម្គាល់ឃើញថាព្រះយេស៊ូវមានឪពុកម្តាយដែលមានសេចក្តីស្រលាញ់ និងកោតខ្លាចព្រះ ព្រមទាំងមានសាច់ញាតិជាអ្នកបែបនោះដែរ។ ដូចជាក្មេងជនជាតិយូដាភាគច្រើនដែរ ព្រះអង្គប្រហែលជាចូលរៀននៅសាលាប្រជុំ ជាកន្លែងដែលព្រះអង្គបានរៀនអាន និងទន្ទេញបទគម្ពីរចេញពីគម្ពីរក្រឹត្យវិន័យ និងពាក្យទំនាយហោរា។ ព្រះអង្គមានកិច្ចការដែលបានរួមចំណែកជួយគ្រួសារ និងសហគមន៍របស់ព្រះអង្គ។ ព្រះអង្គមានទីជម្រក អាហារ និងសម្លៀកបំពាក់។ របស់ទាំងអស់នោះសាមញ្ញ ប៉ុន្តែគ្រប់គ្រាន់ ដូចដែលយើងបានដឹងរួចមកហើយ។

ប្រសិនបើគំរូទាំងនេះចេញពីជីវិតរបស់ព្រះយេស៊ូវតំណាងឱ្យព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់ ទាំងអស់នេះគួរតែឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងការយកចិត្តទុកដាក់ និងព័ន្ធកិច្ចរបស់ពួកជំនុំ។ ប្រាកដណាស់ ភាពទ័លក្រខាងសាច់ឈាម*មិនមែន*ជាគោលបំណងរបស់ព្រះជាម្ចាស់ទេ ហើយគ្រីស្ទបរិស័ទទាំងអស់គួរតែធ្វើការប្រឆាំងនឹងភាពទ័លក្រ ដោយចងចាំថា ព្រះជាម្ចាស់គឺជាអ្នកដែលផ្គត់ផ្គង់សេចក្តីត្រូវការដែលធម្មតា និងដែលអស្ចារ្យ។ តើពួកជំនុំរបស់យើងកំពុងធ្វើអ្វី ដើម្បីធានាថា មានធនធានគ្រប់គ្រាន់សម្រាប់ការវិវឌ្ឍន៍របស់មនុស្សនៅក្នុងពួកជំនុំ និងសហគមន៍របស់យើង? គ្រីស្ទបរិស័ទដែលមានលើសមានការទទួលខុសត្រូវជួយបងប្អូនប្រុសស្រីដែលខ្វះ

ខាត ប៉ុន្តែសូម្បីតែពួកជំនុំដែលក្រក៏មិនត្រូវបានលើកលែងពីបញ្ញត្តិនៅក្នុងព្រះគម្ពីរដែរ។ ពួកជំនុំដែលក្រទ្រព្យសម្បត្តិត្រូវដឹងថា ភាពទ័លក្រមិនមែនជាគោលបំណងរបស់ព្រះជាម្ចាស់ទេ និងដឹងថា ព្រះជាម្ចាស់សន្យាថានឹងផ្គត់ផ្គង់ឱ្យ នៅពេលដែលយើងរស់នៅតាមរបៀបដែលព្រះអង្គត្រាស់ហៅយើង។ ព្រះជាម្ចាស់ស្ទើរតែត្រាស់ហៅឱ្យធ្វើជាដៃគូជាមួយព្រះអង្គជានិច្ចនៅក្នុងការប្រោសយើងឱ្យជា។ ដូច្នេះហើយ ពួកជំនុំដែលនៅក្នុងចំណោមអ្នកដែលទ័លក្រ ត្រូវធ្វើអ្វីដែលពួកគេអាចធ្វើបាន ខណៈពេលដែលទុកចិត្តថា ព្រះជាម្ចាស់នឹងអន្តរាគមន៍ ហើយផ្គត់ផ្គង់អ្វីដែលត្រូវការ ជាការឆ្លើយតបទៅនឹងការស្តាប់បង្គាប់របស់ពួកគេ។

## ការវិវឌ្ឍន៍ឡើងមានគោលបំណង

ការរីកចម្រើនឡើងមិនមែនសម្រាប់តែការរីកចម្រើនឡើងប៉ុណ្ណោះទេ។ ការអភិវឌ្ឍន៍មានគោលបំណង។ ព្រះយេស៊ូវបានចម្រើនឡើងដោយមានគោលបំណង គឺព្រះអង្គបានវិវឌ្ឍឡើងឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ព្រះអង្គ។ បទគម្ពីរពណ៌នាអំពីគោលបំណងនោះតាមរបៀបជាច្រើន។ "ពីព្រោះខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែននឹងធ្វើតាមចិត្តខ្ញុំទេ *គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ចាត់ឱ្យខ្ញុំមក*" (យ៉ូហាន ៦:៣៨)។ " ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំ *អោយផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ* ទ្រង់បានចាត់ខ្ញុំ *អោយមកដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ និងសេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយអោយដោះមនុស្សដែលត្រូវគេជិះជាន់អោយរួច ព្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះអម្ចាស់កំណត់ទុក*" ( លូកា ៤:១៨-១៩)។ "ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ឱ្យមកក្នុងលោកិយ ដើម្បីនឹងជំនុំជំរះលោកិយនោះទេ *គឺឱ្យលោកិយបានសង្គ្រោះដោយសារទ្រង់វិញ*" (យ៉ូហាន ៣:១៧)។ "អ្នកណាក្នុងពួកអ្នករាល់គ្នាដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ ហើយអ្នកណាក្នុងពួកអ្នកដែលចង់បានជាលេខ១ អ្នកនោះត្រូវធ្វើជាបាវដល់អ្នករាល់គ្នាវិញដែរ *ដូចជាកូនមនុស្សបានមក មិនមែនអោយគេបំរើលោកទេ គឺនឹងបំរើគេវិញ* ហើយនិងអោយជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង" (ម៉ាថាយ ២០:២៥-២៨)។

មានពាក្យមួយដែលសង្ខេបគោលបំណងរបស់ព្រះយេស៊ូវបានយ៉ាងល្អ គឺការបម្រើ។ ព្រះយេស៊ូវបានរីកចម្រើនឡើង ឬបានវិវឌ្ឍឡើងដើម្បីបម្រើ។ ដោយព្រោះយើងត្រូវបានបង្កើតមកដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីអត្តចរិតរបស់ព្រះគ្រីស្ទ គឺរូបអង្គរបស់ព្រះ យើងក៏ត្រូវបានដាក់នៅទីនេះដើម្បីបម្រើផងដែរ។ ការបម្រើគឺជាសញ្ញាសំគាល់អំពីភាពធំឧត្តម ភាពពេញវ័យ និងការវិវឌ្ឍន៍របស់មនុស្សពិតប្រាកដ។ ជាការសំខាន់ណាស់ដែលត្រូវកត់សម្គាល់ថា មានការបម្រើពីរប្រភេទ។ ប្រភេទមួយគឺជាការមិនស្ម័គ្រចិត្ត ឬទាសភាព។ វប្បធម៌ដែលមានប្រវត្តិទាសភាពប្រហែលជាពិបាកនឹង

មើលឃើញការបម្រើតាមបែបវិជ្ជមានណាស់ ។ ទោះបីយ៉ាងណាក៏ដោយ ការបម្រើដែលព្រះគម្ពីរនិយាយខុសប្លែកពីនោះ គឺជាការបម្រើស្ម័គ្រចិត្តនៅក្នុងភីលីព ២ ។ នោះគឺជាឥរិយាបថព្រមស្ដាប់បង្គាប់ដែលឆ្លុះបញ្ចាំងឱ្យឃើញពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដាក់អ្នកដទៃមុន និងប្រព្រឹត្តចំពោះពួកគេដូចដែលយើងចង់ឱ្យពួកគេប្រព្រឹត្តចំពោះយើង ។

តើយើងដឹងយ៉ាងដូចម្ដេចថា មនុស្សកំពុងធ្វើដំណើរឆ្ពោះទៅរកការវិវឌ្ឍន៍តាមបែបព្រះគម្ពីរ? គឺនៅពេលដែលយើងឃើញពួកគេលះបង់បម្រើនៅក្នុងពិភពលោករបស់ពួកគេ ដូចដែលព្រះគ្រីស្ទបានបម្រើនៅក្នុងពិភពលោករបស់ព្រះអង្គ ។ ប៉ុន្តែ សូមទៅមុខមួយជំហានទៀត ។ ប្រសិនបើគោលបំណងរបស់យើងគឺបម្រើ តើការបម្រើរបស់យើងមានគោលបំណង ឬគោលដៅយ៉ាងដូចម្ដេច? គឺជួយមនុស្សដទៃទៀតធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ ។ តើគោលបំណងទាំងនោះមានអ្វីខ្លះ? ដើម្បីត្រលប់ដូចជាព្រះគ្រីស្ទ គឺបម្រើ ។ នៅពេលដែលរាស្ត្ររបស់ព្រះជាម្ចាស់គឺជាអ្នកបម្រើ ព្រះអង្គនឹងបានទទួលសិរីល្អ ។ ហើយនោះគឺជាគោលដៅពិតប្រាកដចុងក្រោយរបស់គ្រីស្ទបរិស័ទទាំងអស់ គឺថ្វាយសិរីល្អដល់ព្រះវរបិតារបស់យើងដែលគង់នៅឯស្ថានសួគ៌ ។

## និយមន័យនៅក្នុងព្រះគម្ពីរសម្រាប់ការវិវឌ្ឍន៍

ដោយព្រោះយើងកំពុងមើលការវិវឌ្ឍន៍របស់មនុស្សចេញពីគំរូនៅក្នុងលូកា ២:៥២ យើងអាចឱ្យនិយមន័យការវិវឌ្ឍន៍របស់មនុស្សថាជាការធ្វើដំណើរចេញពីកន្លែងដែលយើងនៅនៅពេលបច្ចុប្បន្ននេះឆ្ពោះទៅរកគោលបំណងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគតរបស់ព្រះជាម្ចាស់សម្រាប់យើង ។ ការធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់គឺជាដំណើរពេញមួយជីវិត! ការទាំងអស់នេះមិនមែនកើតឡើងភ្លាមទេ ហើយនឹងមិនចប់ក្នុងពេលដែលយើងរស់នៅឡើយ រហូតដល់ពេលយើងជួបព្រះគ្រីស្ទមុខទល់នឹងមុខ ។ ទម្រាំដល់ពេលនោះ យើងនៅក្នុងដំណើរការនោះជានិច្ច គឺការធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់ ។ តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្ដេចសម្រាប់យើង? យើងដឹងថា គោលបំណងទាំងនោះរួមមានការបម្រើ គឺការបម្រើអ្នកដទៃទៀត ។

តើយើងចាប់ផ្ដើមនៅកន្លែងណា? គ្រីស្ទបរិស័ទត្រូវឆ្លុះបញ្ចាំងពីអត្តចរិតនៃព្រះរបស់ពួកគេ ។ ដូច្នេះហើយ យើងចង់ជួយមនុស្សដទៃទៀតឱ្យរីកចម្រើនឡើងឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ ។ ទោះបីយ៉ាងណាក៏ដោយ មានជំហានមួយដែលត្រូវកើតឡើងផងដែរ មុនពេលដែលយើងលើកទឹកចិត្តឱ្យមានការរីកចម្រើនឡើងនៅក្នុងមនុស្សដទៃទៀត ហើយជំហាននោះគឺជាការរីកចម្រើនឡើងផ្ទាល់ខ្លួនរបស់យើង ។ ព្រះយេស៊ូវបានប្រាប់យើងថា អ្នកដែលធំនៅក្នុងនគររបស់ព្រះអង្គគឺជាអ្នកដែលធ្វើមុនសិន ទើបបង្រៀន (ម៉ាថាយ ៥:១៩) ។ សិស្សដែលមានប្រសិទ្ធភាពនឹងជាអ្នកដែលធ្វើជាគំរូអំពីការរីកចម្រើនឡើង ដែលខ្លួនកំពុងលើកទឹកចិត្តឱ្យមាននៅក្នុងអ្នកដទៃ

ទៀត។ យើងមិនអាចចាំទាល់តែរីកចម្រើនឡើងចប់សព្វគ្រប់ ទើបយើងលើកទឹកចិត្ត និងជួយអ្នកដទៃទៀតឱ្យឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេនោះឡើយ ប៉ុន្តែយើងខ្លួនឯងត្រូវស្ថិតនៅក្នុងដំណើរការនោះ មុនពេលដែលយើងអាចលើកទឹកចិត្ត និងជួយអ្នកទៃទៀតនៅក្នុងការរីកចម្រើនឡើងរបស់ពួកគេ។

យើងមានពាក្យស្លោកមួយនិយាយថា "ការវិវឌ្ឍន៏ចាប់ផ្តើមឡើងជាមួយខ្ញុំ"។ ចូរយើងសូមព្រះវិញ្ញាណបរិសុទ្ធឱ្យបង្ហាញប្រាប់ផ្នែកដែលព្រះអង្គចង់ឱ្យយើងរីកចម្រើនឡើង។ នៅពេលដែលព្រះអង្គបង្ហាញផ្នែកដែលយើងត្រូវរីកចម្រើនឡើង យើងត្រូវសម្រេចចិត្តធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គ។ ផ្នែក និងល្បឿននៃការផ្លាស់ប្តូរនឹងខុសពីគ្នាសម្រាប់អ្នកជឿម្នាក់ៗ។ ទោះបីយ៉ាងណាក៏ដោយ ការធ្វើដំណើរឆ្ពោះទៅរកការវិវឌ្ឍន៍នឹងនៅក្នុងទិសដៅដដែលជានិច្ច ដោយឆ្ពោះទៅរកគំរូដែលយើងមើលឃើញនៅក្នុងព្រះគ្រីស្ទ។

សូមព្រះជាម្ចាស់ប្រទានព្រះគុណ និងកម្លាំងដល់យើង ដើម្បីធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គជាពិសេសការបម្រើដល់អ្នកដទៃទៀត។ ប៉ុន្តែ សូមយើងប្រុងប្រយ័ត្ននៅក្នុងការបម្រើដល់អ្នកដទៃទៀត ប្រសិនបើយើងមិនធ្វើដំណើរជានិច្ចឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គសម្រាប់យើងនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់យើងនោះ។

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ 85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាត: លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាមទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១000 ច្បាប់។*

## ធនធានល្អដែលបានផ្ដល់ជាយោបល់ជូនៈ

Moffitt, Bob, Tesch, Karla. *If Jesus Were Mayor: How Your Local Church Can Transform Your Community.* Oxford, UK: Monarch Books, 2006, pp. 87-97.

Moffitt, Bob. *What kind of churches and What Kind of Disciples?* A background paper.

Oliveira, Eli. *Irreducible Minimum.* An article.

Harvest Foundation. *Leadership Development Training Program.* www.harvestfoundation.org. Section: Materials, pp. 26-39.

Disciple Nations Alliance online course. www.disciplenations.org/resources/course. Section: *Wholistic Ministry*.